ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ២២៤ សហវ.

# ប្រកាស
## ស្តីពី
## ការបង្កើតផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិត

*************

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ៧៦៥សហវ.ពដ.ចុះថ្ងៃទី១២ ខែតុលាឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបង្កើតអង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធធំ និង អង្គភាពគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម
- បានឃើញ តម្រូវការនៃការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមលិខិតស្នើរបស់ប្រធាននាយកដ្ឋានពន្ធដារ

## សំរេច:

**ប្រការ១:** ត្រូវបានបង្កើតផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិតនៅក្នុងសាខាពន្ធដារខេត្តបន្ទាយមានជ័យ-កំពង់ស្ពឺ-កំពង់ឆ្នាំង-កណ្ដាល និង ស្វាយរៀង ដើម្បីគ្រប់គ្រង និង ប្រមូលពន្ធចំពោះសហគ្រាស ក្រោមគ្រប់ទ្រង់ទ្រាយ ដែលត្រូវជាប់ពន្ធតាមរបបពិត ហើយមានទីស្នាក់ការជាគោលដើមនៅក្នុងខេត្តរបស់ខ្លួន ។

**ប្រការ២:** ផ្នែកគ្រប់គ្រង និង ប្រមូលពន្ធតាមរបបពិតដូចមានចែងក្នុងប្រការ១ខាងលើ រួមមាន៤ក្រុម:

- ក្រុមចុះបញ្ជី និង សេវាអ្នកជាប់ពន្ធ
- ក្រុមចាត់ចែងលិខិតប្រកាស និង ប្រមូលពន្ធ
- ក្រុមតឹងទារប្រាក់ពន្ធ
- ក្រុមសវនកម្មសារពើពន្ធ ។

**ប្រការ៣:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និង អង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០២

**គាត ឈន់**

**ចម្លងជូន:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត ដែលពាក់ព័ន្ធ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
- អង្គភាពពន្ធដារ ដែលពាក់ព័ន្ធ
  " ដើម្បីអនុវត្ត "
- កាលប្បវត្តិ-ឯកសារ